ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# <u>កិច្ចព្រមព្រៀងសះជាលើករណីដីចម្ការពាក់ព័ន្ធ(ចំនាស់) របស់សហគមន៍ភូមិពូទឹតជាមួយក្រុមហ៊ុនវ៉ារ៉ាណាស៊ី និងក្រុមហ៊ុនសេដ្ឋិកុលា</u>

# <u>Settlement Agreement on related farmland of Community of Pu Teut Village with Varanasi Company and Sethikula Company</u>

កិច្ចព្រមព្រៀងនេះធ្វើនៅស្រុកពេជ្រាដា ខេត្តមណ្ឌលគីរី, នាថ្ងៃទី២១... ខែ.កញ្ញា... ឆ្នាំ២០២១

This Agreement is entered into Pichreada District, Mondulkiri province, on the 21st....Sep. 2021

**រវាង**

**Between**

ភាគីតំណាងសហគមន៍លើករណីដីចម្ការពាក់ព័ន្ធរបស់សហគមន៍ភូមិពូទឹត រួមមាន៖

The community party representing the land related farmland of Community of Pu Teut village includes:

១). ឈ្មោះ **ង៉ាន យីន** (Ngang Yin) ភេទ ស្រី កើតឆ្នាំ [redacted] មានតួនាទីជា ប្រធានគណកម្មការត្រីភាគី

1. Ngang Yin, female, born in [redacted], Head of the Tripartite Committee;

២). ឈ្មោះ **ធីន ស៊ីម៉ា** (Thin Sima) ភេទ ស្រី កើតឆ្នាំ [redacted] មានតួនាទីជា តំណាងសហគមន៍

2. Thin Sima, female, born in [redacted], representative of the community;

៣). ឈ្មោះ **ធឿន ម៉ាប់** (Theoun Mab) ភេទ ប្រុស កើតឆ្នាំ [redacted] មានតួនាទីជា តំណាងសហគមន៍

3. Theoun Mab, male, born in [redacted] representative of the community;

៤). ឈ្មោះ **គប់ លេត** (Korb Let) ភេទ ស្រី កើតឆ្នាំ [redacted] មានតួនាទីជា តំណាងសហគមន៍

4. Korb Let, female, born in [redacted], representative of the community;

៥). ឈ្មោះ **កេត ផល្លីត** (Ket Phallit) ភេទ ប្រុស កើតឆ្នាំ [redacted] មានតួនាទីជាតំណាងសហគមន៍



**First-Class Solutions Ltd.**, registered under No. Co. 13113/09P
with the Ministry of Commerce of the Kingdom of Cambodia

#12 Street 222, Phnom Penh, Cambodia
+855 23 214 142 / 12 925 789 / 18 960 748 / 78 567 863
fcinfo@firstclass.com.kh | www.firstclass.com.kh
(IMG2021)

Phnom Penh, September 17, 2021
*This is to certify that this translation correctly corresponds to all the essential particulars of the attached document. It does not establish the authenticity of the original document or the correctness of the contents herein.*

FIRST-CLASS SOLUTIONS LTD

**CHAN Sopheap**, Translation PM **LIM Kruy**, CEO

5. Ket Phallit, male, born in [redacted], representative of the community,

មានទីលំនៅបច្ចុប្បន្ននៅភូមិពូទឺត ឃុំប៊ូស្រា ស្រុកពេជ្រាដា ខេត្តមណ្ឌលគីរី ហៅកាត់ថា "**ភាគីសហគមន៍**" ។

Currently residing in Pu Teut village, Busra commune, Pichreada district, Mondulkiri province, referred to as "**The Community Party**".

**និង**

And

**ក្រុមហ៊ុន វ៉ារ៉ាណាស៊ី** មានអាសយដ្ឋានក្រុមហ៊ុនស្ថិតនៅផ្ទះលេខ[redacted] ផ្លូវលេខ[redacted]ក្រុម[redacted] សង្កាត់[redacted] ខណ្ឌ[redacted] និង**ក្រុមហ៊ុនសេដ្ឋីកុលា** មានអាសយដ្ឋានក្រុមហ៊ុនស្ថិតនៅផ្ទះលេខ[redacted] ផ្លូវលេខ[redacted] ក្រុម[redacted] សង្កាត់[redacted] ខណ្ឌ[redacted]មានអ្នកតំណាងរួមគ្នា ដោយលោក[redacted]កើតឆ្នាំ[redacted] កាន់លិខិតឆ្លងដែនលេខ[redacted] ចុះ ថ្ងៃទី[redacted]ចេញឱ្យដោយប្រទេស[redacted]និង កញ្ញា[redacted]កើតឆ្នាំ[redacted] កាន់លិខិតឆ្លង ដែនលេខ[redacted] ចុះថ្ងៃទី[redacted] ចេញឱ្យដោយប្រទេស[redacted]ដែលជាភាគីវិវាទ ហៅកាត់ថា "**ភាគីក្រុមហ៊ុន**" ។

**Varanasi Co., Ltd.**, with its address at House,[redacted] street[redacted], group[redacted] quarter, [redacted] District, [redacted] and **Sethikula Co., Ltd.**, with its address at House,[redacted] street[redacted] group[redacted] quarter,[redacted] District, [redacted] jointly represented by [redacted] born in[redacted], holding Passport No.[redacted] issued on[redacted] by[redacted] and [redacted], born in[redacted], holding Passport No. [redacted] issued on [redacted] by[redacted], as disputing party referred to as "**The Company Party**".

**ភាគីទាំងអស់ បានព្រមព្រៀងសះជាគ្នាដូចតទៅ៖**

**The Parties agreed to settle as follows:**

### ប្រការ ១.- កម្មវត្ថុនៃកិច្ចព្រមព្រៀង

### Article 1.- Subject of the Agreement

កិច្ចព្រមព្រៀងនេះសម្រេចបានតាមរយៈដំណើរការសម្រុះសម្រួលរវាងភាគីសហគមន៍ និងភាគីក្រុមហ៊ុន។

កិច្ចព្រមព្រៀងនេះបានដោះស្រាយការទាមទារពីសមាជិកសហគមន៍ដែលបានចូលរួមក្នុងដំណើរការ



first class
in pursuit of speed and quality

**First-Class Solutions Ltd.**, registered under No. Co. 13113/09P with the Ministry of Commerce of the Kingdom of Cambodia

#12 Street 222, Phnom Penh, Cambodia
+855 23 214 142 / 12 925 789 / 18 960 748 / 78 567 863
fcinfo@firstclass.com.kh | www.firstclass.com.kh
*(IMG2021)*

Phnom Penh, September 17, 2021
*This is to certify that this translation correctly corresponds to all the essential particulars of the attached document. It does not establish the authenticity of the original document or the correctness of the contents herein.*

FIRST-CLASS SOLUTIONS LTD

**CHAN Sopheap**, Translation PM **LIM Kruy**, CEO

សម្រុះសម្រួលទាក់ទងនឹងសំណងពីមុនរបស់បគ្គលនីមួយៗ និងដីចម្ការគ្រួសាររបស់ពួកគេ។ ការទាមទារទាំងនេះរួមមាន ប៉ុន្តែមិនកំណត់ចំពោះតែ៖

This agreement was reached through the mediation process between **the Community Party** and **the Company Party**. It settles claims from community members joining the mediation process in relation to past compensation of individual and family farmland. These claims include, but are not limited to:

- ការទាមទារពីសមាជិកសហគមន៍ចំពោះដីចម្ការដែលត្រូវបានគេរាយការណ៍ថាមិនទាន់បានទទួលសំណង

  Claims from the community members for land that was reportedly not compensated
- ការទាមទារពីសមាជិកសហគមន៍ទាក់ទងនឹងប្រភេទសំណងណាមួយដែលទទួលបានមុនកិច្ចព្រមព្រៀងនេះ៖ ដូចជាការទាមទារពីទំហំដីដែលបានផ្តល់សំណង ចំនួនទឹកប្រាក់សំណង ឬលក្ខខណ្ឌណាមួយនៃកិច្ចព្រមព្រៀងសំណងអតីតកាល
- Claims from the community members regarding any type of compensation received prior to this agreement: such as claims on the size of the compensated land, the amount of the compensation or any terms of past compensation agreements.

ភាគីសហគមន៍ និងភាគីក្រុមហ៊ុន យល់ព្រម និងឯកភាពគ្នាលើចំណុចសះជារួមគ្នាមួយចំនួនដូចខាងក្រោមនេះ៖

**The Community Party** and **the Company Party** agree and approve the common settled issues as below:

### ១.១.- ការផ្តល់ជូនថវិកា

### 1.1.- The provision of budget

**ភាគីទាំងអស់** បានព្រមព្រៀងគ្នាដោយភាគីក្រុមហ៊ុនឯកភាពផ្តល់នូវថវិកា ជូនដល់ភាគីសហគមន៍ ចំនួន ១៣ ០០០ (មួយម៉ឺនបីពាន់) ដុល្លារអាមេរិក ក្នុងមួយឆ្នាំ សម្រាប់រយៈពេល៥ឆ្នាំ ដែលគិតជាថវិកាសរុបចំនួន ៦៥០០០ (ប្រាំមួយម៉ឺនប្រាំពាន់) ដុល្លារអាមេរិក។

**All parties** agreed that **the Company Party** agrees to provide **the Community Party** with a budget of 13,000 (thirteen thousand) US dollars per year allocated for a period of 5 years, equivalent to a total amount of 65000 (sixty five thousand) US dollars.

### ១.២.- ពេលវេលានៃការប្រើប្រាស់ថវិកា

### 1.2.- The duration of using budget

- ថវិកានេះនឹងត្រូវផ្តល់ជូនជារៀងរាល់ឆ្នាំ សម្រាប់រយៈពេល៥ឆ្នាំ ដោយចាប់ផ្តើមពី ខែមករា ឆ្នាំ ២០២២ ដល់ខែធ្នូ ឆ្នាំ ២០២៦។



first class
in pursuit of speed and quality

**First-Class Solutions Ltd.**, registered under No. Co. 13113/09P
with the Ministry of Commerce of the Kingdom of Cambodia

#12 Street 222, Phnom Penh, Cambodia
+855 23 214 142 / 12 925 789 / 18 960 748 / 78 567 863
fcinfo@firstclass.com.kh | www.firstclass.com.kh
*(IMG2021)*

Phnom Penh, September 17, 2021
*This is to certify that this translation correctly corresponds to all the essential particulars of the attached document. It does not establish the authenticity of the original document or the correctness of the contents herein.*

FIRST-CLASS SOLUTIONS LTD

**CHAN Sopheap**, Translation PM **LIM Kruy**, CEO

This budget shall be allocated yearly for a period of 5 years starting from January 2022 to December 2026.

- ការផ្ដល់ថវិកាដែលសល់ ឬថវិកាដែលប្រើប្រាស់មិនអស់ក្នុងរយៈពេល ៥ឆ្នាំ **ភាគីទាំងអស់**ព្រមព្រៀងគ្នា ដូចខាងក្រោម៖

  The remaining budget or budget that have not been used after 5 years, **all parties** agree as follows:

  - ប្រសិនបើថវិកាសរុបប្រចាំឆ្នាំដែលផ្ដល់ដោយក្រុមហ៊ុនមិនបានចំណាយអស់ ដូច្នេះចំនួនថវិកាដែលនៅសល់ នឹងរក្សាទុកដោយភាគីក្រុមហ៊ុន ដើម្បីឲ្យភាគីសហគមន៍មានសិទ្ធិប្រើប្រាស់បន្ទាប់ពីបញ្ចប់រយៈពេល ៥ឆ្នាំ។

    If the total yearly budget provided by the company is not spent, the remaining amount will be kept by **the Company Party** to be used by **the Community Party** after the end of 5 years allocating period.

  - ថវិកាដែលនៅសល់នេះ និងរបៀបដែលនឹងត្រូវចំណាយនឹងត្រូវពិភាក្សាឡើងវិញរវាងភាគីក្រុមហ៊ុន និងភាគីសហគមន៍ បន្ទាប់ពីរយៈពេល ៥ឆ្នាំ ដោយផ្អែកលើលំហូរសាច់ប្រាក់របស់ភាគីក្រុមហ៊ុន។

    The remaining budget and how it will be spent shall be re-discussed, after the 5 years, between **the Company Party and the Community Party** depending on the company cash flow.

  - ការបែងចែកថវិកាដែលនៅសល់នឹងមិនត្រូវលើស ១៣ ០០០ (មួយម៉ឺនបីពាន់) ដុល្លារអាមេរិកក្នុងមួយឆ្នាំ។

    The re-allocation of the remaining budget will not exceed 13000 (thirteen thousand) US dollars per year.

### ១.៣.- គោលបំណងនៃការផ្ដល់ថវិកា

### 1.3.- Purpose of the budget

- ថវិកាប្រចាំឆ្នាំនឹងត្រូវប្រើប្រាស់សម្រាប់សកម្មភាពអភិវឌ្ឍសហគមន៍ (គម្រោង) ដើម្បីបម្រើដល់គ្រួសារនៃ សហគមន៍ដែលចូលរួមក្នុងដំណើរការសម្រុះសម្រួល ។

  The yearly budget shall be used for community development activities (projects) to serve the families participating in the mediation process.

- សកម្មភាពអភិវឌ្ឍសហគមន៍អាចគ្របដណ្ដប់លើប្រធានបទជាច្រើន ដោយមិនកំណត់ទៅលើតែ ការងារហេដ្ឋារចនាសម្ព័ន្ធ ការគាំទ្រកសិកម្ម ការអប់រំ ការអភិវឌ្ឍជំនាញ គម្រោងចិញ្ចឹមជីវិត



first class
in pursuit of speed and quality

**First-Class Solutions Ltd.**, registered under No. Co. 13113/09P
with the Ministry of Commerce of the Kingdom of Cambodia

#12 Street 222, Phnom Penh, Cambodia
+855 23 214 142 / 12 925 789 / 18 960 748 / 78 567 863
fcinfo@firstclass.com.kh | www.firstclass.com.kh
*(IMG2021)*

Phnom Penh, September 17, 2021
*This is to certify that this translation correctly corresponds to all the essential particulars of the attached document. It does not establish the authenticity of the original document or the correctness of the contents herein.*

FIRST-CLASS SOLUTIONS LTD

**CHAN Sopheap**, Translation PM **LIM Kruy**, CEO

សកម្មភាពអេកូទេសចរណ៍ ជំនួយសង្គ្រោះបន្ទាន់ ឬជំនួយជាថវិកាដល់មូលនិធិដែលគ្រប់គ្រងដោយសហគមន៍នោះទេ ក្នុង ន័យនេះភាគីសហគមន៍អាចស្នើសុំថវិកានេះយកមកប្រើប្រាស់បានយ៉ាងទូលំទូលាយ សម្រាប់ការងារអភិវឌ្ឍន៍ ផ្សេងៗក្នុងសហគមន៍តាមតម្រូវការរបស់ខ្លួន។

Community development activities can cover a wide range of topics, including but not limited to: infrastructure work, agricultural support, education, skill development, livelihoods projects, eco-tourism activities, emergency relief or financial support to a community-managed fund. In this sense, **the Community Party** can request this budget to be widely used for various development works in the community according to their needs.

- ថវិកាអាចត្រូវបានបែងចែកសម្រាប់សកម្មភាពច្រើនជាងមួយ ក្នុងរយៈពេលមួយឆ្នាំ។

  The budget can be divided for more than one activity through the year.

- ការចូលរួមចំណែកជាសាច់ប្រាក់ដល់មូលនិធិគ្រប់គ្រងដោយសហគមន៍ ឬថវិកាដែលផ្តល់ជូនដល់សហគមន៍ ដោយផ្ទាល់ នឹងមិនលើសពី២៥%នៃថវិកាប្រចាំឆ្នាំ ឬមិនលើសពីថវិកា ចំនួន ៣២៥០ (បីពាន់ពីររយហាសិប) ដុល្លារអាមេរិក ក្នុង មួយឆ្នាំ។

  Cash contribution to a community-managed fund will not exceed 25% of the annual budget or will not exceed the amount of 3250 (three thousand two hundred and fifty) US dollars per year.

- ភាគីសហគមន៍ត្រូវយល់ថាលំហូរសាច់ប្រាក់អាចទទួលបានអាស្រ័យលើចំនួននៃសំណើដែលភាគីសហគមន៍ បានដាក់ជូនទៅភាគីក្រុមហ៊ុន តាមរយៈពេលដែលបានកំណត់។

  Community shall understand that the cash flow available depends on the number of proposals submitted to the company by all the communities on a given period of time.

### ១.៤.- ការអនុវត្តគម្រោងថវិកា

### 1.4.- Implementation of the project budget

- ការអនុវត្តគម្រោងថវិកានឹងគោរពទៅតាមដំណើរការដូចខាងក្រោម៖

  The implementation of project budget shall conform to the following process:

  - ជំហានដំបូង ភាគីសហគមន៍ត្រូវដាក់សំណើទៅភាគីក្រុមហ៊ុនសម្រាប់សកម្មភាពអភិវឌ្ឍសហគមន៍ (គម្រោង) ជាលាយលក្ខអក្សរ ក្នុងករណីនេះសំណើត្រូវចុះហត្ថលេខាដោយតំណាងសហគមន៍ទាំងអស់ដែលបានចូលរួមក្នុងការសម្រុះសម្រួល។

    First, **the Community Party** shall submit to **the Company Party** a written proposal for a community development activity (project). The proposal shall be signed by all representatives of the community in the mediation.



first class in pursuit of speed and quality

**First-Class Solutions Ltd.**, registered under No. Co. 13113/09P with the Ministry of Commerce of the Kingdom of Cambodia

#12 Street 222, Phnom Penh, Cambodia
+855 23 214 142 / 12 925 789 / 18 960 748 / 78 567 863
fcinfo@firstclass.com.kh | www.firstclass.com.kh
(IMG2021)

Phnom Penh, September 17, 2021
*This is to certify that this translation correctly corresponds to all the essential particulars of the attached document. It does not establish the authenticity of the original document or the correctness of the contents herein.*

ហ្វឺស-គ្លាស សូលូសិន អេលធីឌី FIRST-CLASS SOLUTIONS LTD.

CHAN Sopheap, Translation PM — LIM Kruy, CEO

- ភាគីសហគមន៍ ត្រូវដាក់សំណើថវិកាមួយសម្រាប់សកម្មភាពអភិវឌ្ឍន៍សហគមន៍មួយ (គម្រោង)។

  **The Community Party** shall submit one proposal covering <u>one</u> community development activity (project).

- ភាគីសហគមន៍ អាចធ្វើការដាក់សំណើជាច្រើនព្រមគ្នា ក្នុងរយៈពេលមួយឆ្នាំបាន។

  **The Community Party** can submit several proposals through the year.

- **ភាគីទាំងអស់** នឹងចូលរួមពិភាក្សាជាមួយគ្នា និងវាយតម្លៃលើសំណើដែលដាក់មកនេះ រួមទាំងមធ្យោបាយល្អ បំផុតក្នុងការអនុវត្តសកម្មភាព រយៈពេលអនុវត្ត ថវិកា និងដំណើរការ ហើយការវាយតម្លៃ និងការពិភាក្សាគ្នានេះ មិនគួរលើសពី០២(ពីរ)ខែ សម្រាប់គម្រោងថវិកាដែលបានស្នើឡើង។

  **All Parties** shall discuss together and evaluate the proposal including the best way to conduct the activity, its implementation period, budget and process. The Evaluation and discussion should not exceed 2 (two) months for the proposed project budget.

- បន្ទាប់ពីដំណាក់កាលវាយតម្លៃបានបញ្ចប់ ភាគីសហគមន៍ និងភាគីក្រុមហ៊ុន នឹងបង្កើតកិច្ចសន្យារួម ដោយផ្តល់ព័ត៌មានលម្អិតដូចជា ការអនុវត្តគម្រោង ការកំណត់ពេលវេលា ឬចំនួនថវិកាដែលគ្រោងទុក ដោយកិច្ចសន្យារួមនេះនឹងត្រូវចុះហត្ថលេខា ឬផ្តិតមេដៃដោយ**ភាគីទាំងពីរ** និងទំនាក់ទំនងទៅ**អាជ្ញាធរមូលដ្ឋាន**។

  Upon the completion of the evaluation phase, **the Community Party** and **the Company Party** shall establish a joint agreement detailing information such as its implementation, timeline or planned budget. The joint agreement shall be signed or thumb printed by **both parties** and communicated to the **local authorities**.

### ១.៥.- ដំណាក់កាលអនុវត្តគម្រោងដែលបានស្នើឡើង

### 1.5.- Implementation phase of the proposed project

- នៅក្នុងអំឡុងពេលនៃការអនុវត្តគម្រោង ភាគីសហគមន៍ត្រូវផ្តល់ភស្តុតាងពាក់ព័ន្ធទាំងអស់ដែលគម្រោងនឹងត្រូវបានអនុវត្តស្របតាមកិច្ចសន្យារួម ដូចជាវិក័យប័ត្រ រូបថត បញ្ជីអ្នកទទួល។ល។ ក្នុងករណីនេះ ភាគីក្រុមហ៊ុនត្រូវ បានអនុញ្ញាតឱ្យចូលមើលសកម្មភាពនេះដោយផ្ទាល់បាន។

  During the implementation of the proposed project, **the Community Party** shall provide all relevant proofs that the project is being conducted according to the joint agreement, such as invoices, photos, recipient lists etc. In this case, **the Company Party** shall be allowed to visit the activity in person.

### ១.៦.- ការរួមចំណែកជាសាច់ប្រាក់ដល់មូលនិធិគ្រប់គ្រងដោយសហគមន៍

### 1.6.- Cash contribution to Community Managing Fund



first class
in pursuit of speed and quality

**First-Class Solutions Ltd.**, registered under No. Co. 13113/09P with the Ministry of Commerce of the Kingdom of Cambodia

#12 Street 222, Phnom Penh, Cambodia
+855 23 214 142 / 12 925 789 / 18 960 748 / 78 567 863
fcinfo@firstclass.com.kh | www.firstclass.com.kh
*(IMG2021)*

Phnom Penh, September 17, 2021
*This is to certify that this translation correctly corresponds to all the essential particulars of the attached document. It does not establish the authenticity of the original document or the correctness of the contents herein.*

FIRST-CLASS SOLUTIONS LTD.

**CHAN Sophenn**, Translation PM, **LIM Kruy**, CEO

- ចំពោះការចូលរួមចំណែកជាសាច់ប្រាក់ដល់មូលនិធិគ្រប់គ្រងដោយសហគមន៍ ភាគីសហគមន៍ត្រូវផ្តល់ជូនមកក្រុមហ៊ុននូវសេចក្តីបញ្ជាក់លម្អិតអំពីចំនួនទឹកប្រាក់ដែលបានចំណាយ។ ប្រសិនបើមូលនិធិដែលគ្រប់គ្រងដោយ សហគមន៍ត្រូវបានចែកចាយជាសាច់ប្រាក់រវាងក្រុមគ្រួសារដែលចូលរួមក្នុងការសម្រុះសម្រួល សហគមន៍ត្រូវ ផ្តល់ជូនមកក្រុមហ៊ុននូវបញ្ជីដែលបង្ហាញពីចំនួនទឹកប្រាក់សរុបដែលបានចែកជូន គ្រួសារនីមួយៗ និងចុះហត្ថ លេខាដោយអ្នកទទួលម្នាក់ៗ ដោយមានកាលបរិច្ឆេទបែងចែក។ ក្នុងករណីនេះភាគីក្រុមហ៊ុននឹងត្រូវបានអញ្ជើញឱ្យចូលរួមក្នុងការបែងចែក ដែលនឹងត្រូវធ្វើជា សាធារណៈ។

  For cash contribution to a community-managed fund, **the Community Party** shall provide to **the Company Party** a statement detailing how the amount has been spent. If the community-managed fund is distributed in cash between the families participating in the mediation, **the Community Party** shall provide to **the Company Party** a list detailing the sum distributed to each family and signed by each recipient with the date of distribution. In this case, **the Company Party** shall be invited to the distribution which will be held in public.

**ប្រការ ២.- ឯកសារឧបសម្ព័ន្ធនៃកិច្ចព្រមព្រៀងនេះ**

**Article 2.- Annexes to the agreement**

ភាគីសហគមន៍ និងភាគីក្រុមហ៊ុន យល់ព្រម និងឯកភាពគ្នាទទួលយកនូវឯកសារមួយចំនួនដែលជាឧបសម្ព័ន្ធ នៃកិច្ចព្រមព្រៀងសះជា ដូចខាងក្រោមនេះ៖

The **Community Party** and the **Company Party** agree to recognize the following documents as annexes in the agreements:

- បញ្ជីរាយនាមទិន្នន័យទំហំដីចំការពាក់ព័ន្ធដែលទាមទារដោយសហគមន៍ភូមិពូទឺត ជាមួយ **ក្រុមហ៊ុនវ៉ារ៉ាណាស៊ី និងក្រុមហ៊ុនសេដ្ឋីកុលា**

  List of data related to size of farmland claimed by the community of Pu Teut village with **Varanasi Company** and **Sethikula Company**

- ផែនទីបង្ហាញទីតាំងដីចំការពាក់ព័ន្ធទាមទារដោយសហគមន៍ភូមិពូទឺត ជាមួយ **ក្រុមហ៊ុនវ៉ារ៉ាណាស៊ី និងក្រុមហ៊ុនសេដ្ឋីកុលា**

  Maps showing the locations of farmland claimed by the community of Pu Teut village with **Varanasi Company** and **Sethikula Company**

- លិខិតប្រគល់សិទ្ធិជាអ្នកតំណាងលើករណីដីចម្ការពាក់ព័ន្ធរបស់ភូមិពូទឺត ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៧។

- Letter of authorization as representatives for related claimed farmland of Pu Teut village dated November 18, 2017



first class
in pursuit of speed and quality

**First-Class Solutions Ltd.**, registered under No. Co. 13113/09P with the Ministry of Commerce of the Kingdom of Cambodia

#12 Street 222, Phnom Penh, Cambodia
+855 23 214 142 / 12 925 789 / 18 960 748 / 78 567 863
fcinfo@firstclass.com.kh | www.firstclass.com.kh
(IMG2021)

Phnom Penh, September 17, 2021
*This is to certify that this translation correctly corresponds to all the essential particulars of the attached document. It does not establish the authenticity of the original document or the correctness of the contents herein.*

FIRST-CLASS SOLUTIONS LTD

**CHAN Sopheap**, Translation PM **LIM Kruy**, CEO

- ស្ថិតិសមាជិកគ្រួសារនៃសហគមន៍ភូមិពូទឹត សម្រាប់ករណីដីចំការពាក់ព័ន្ធ។

  List of family members of the community of Pu Teut village for the case of related claimed farmland.
- បញ្ជីឈ្មោះសមាជិកសហគមន៍នៃភូមិពូទឹតដែលព្រមព្រៀងចំពោះលក្ខខ័ណ្ឌនៃកិច្ចព្រមព្រៀង

  List of community members of Pu Teut village who agree to the terms of the agreement
- ឯកសារមួយចំនួនផ្សេងទៀតដែលមានទំនាក់ទំនង ឬពាក់ព័ន្ធនឹងករណីដីចំការពាក់ព័ន្ធរវាងសហគមន៍ភូមិពូទឹត និង **ក្រុមហ៊ុនវ៉ារ៉ាណាស៊ី** និង**ក្រុមហ៊ុនសេដ្ឋីគុលា**។

  Other relevant documents related to farmland related compensation of Pu Teut village with **Varanasi Company** and **Sethikula Company.**

## ប្រការ ៣.- ភាតព្វកិច្ច និងការធានារបស់ភាគីសហគមន៍

## Article 3.- Obligations and Warranties of the Community Party

៣.១- ភាគីសហគមន៍ ត្រូវធានាថាខ្លួនមានសិទ្ធិស្របច្បាប់នៅក្នុងការចុះកិច្ចព្រមព្រៀងនេះ និងមានកាតព្វកិច្ចធានា ថាមិនធ្វើការរំខាន ចំពោះករណីដែលបានដោះស្រាយរួចហើយរបស់ខ្លួនជាមួយភាគីក្រុមហ៊ុនម្តងទៀតទេ។

3.1- **The Community Party** shall warrant that it has the legal right to enter into this Agreement and is obliged to ensure that it will not cause further disturbance to **the Company Party** for the case solved.

៣.២-ភាគីសហគមន៍ធានាថាខ្លួននឹងប្រាប់ ឬពន្យល់ទៅសមាជិកសហគមន៍របស់ខ្លួន និងកូនចៅជំនាន់ក្រោយរបស់ សហគមន៍ឲ្យគោរពនូវរាល់ប្រការនានាដែលមានចែងក្នុងកិច្ចព្រមព្រៀងនេះ។

3.2- **The Community Party** warrants that it will inform or explain to its community members and the younger generations of the community and cause them to honor all the provisions of this Agreement.

៣.៣- ភាគីសហគមន៍មានកាតព្វកិច្ចអនុវត្តនូវគ្រប់ប្រការទាំងអស់ដូចមានចែងនៅក្នុងកិច្ចព្រមព្រៀងនេះ ឲ្យស្រប តាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

3.3- **The Community Party** is obliged to carry out all the provisions of this Agreement in accordance with the laws of the Kingdom of Cambodia.



first class
in pursuit of speed and quality
**First-Class Solutions Ltd.**, registered under No. Co. 13113/09P
with the Ministry of Commerce of the Kingdom of Cambodia
#12 Street 222, Phnom Penh, Cambodia
+855 23 214 142 / 12 925 789 / 18 960 748 / 78 567 863
fcinfo@firstclass.com.kh | www.firstclass.com.kh
*(IMG2021)*

Phnom Penh, September 17, 2021
*This is to certify that this translation correctly corresponds to all the essential particulars of the attached document. It does not establish the authenticity of the original document or the correctness of the contents herein.*

FIRST-CLASS SOLUTIONS LTD

**CHAN Sopheap**, Translation PM **LIM Kruy**, CEO

៣.៤- ភាគីសហគមន៍ យល់ព្រមមិនធ្វើការទាមទារប្រាក់សំណងបន្ថែម ឬប្រាក់ផ្សេងទៀតក្នុងករណីដីដដែលនេះ ឬ ទាមទារដីចម្ការបន្ថែមទៀត ឬទាមទារយកដីចំការពាក់ព័ន្ធរបស់ខ្លួន មកវិញ ជាមួយភាគីក្រុមហ៊ុន ក្នុងលក្ខខណ្ឌនៃដីចំការពាក់ព័ន្ធនេះទេ។

3.4 **The Community Party** agrees not to make any claim for additional compensation or other money in the same land case or additional farmland or to demand the return of its related claimed farmland from **the Company Party** in terms of related claimed farmland.

## ប្រការ ៤.- ភាតព្វកិច្ច និងការធានារបស់ភាគីក្រុមហ៊ុន

## Article 4.- Obligations and Warranties of the Company Party

៤.១- ភាគីក្រុមហ៊ុន សន្យា និងធានាការអនុវត្តនូវកាតព្វកិច្ចរបស់ខ្លួនដូចមានចែងក្នុងប្រការ ១ និង ប្រការ ២ ខាងលើឲ្យបានទៀតទាត់ ពេញលេញ គ្រប់ចំនួន និងតាមពេលវេលាកំណត់នៃការព្រមព្រៀងគ្នានេះ ។

4.1- **The Company Party** promises and guarantees the fulfillment of its obligations as stated in Article 1 and Article 2 above, in full and in accordance with the agreed dates and terms of this Agreement.

៤.២- ភាគីក្រុមហ៊ុនធានាថា ទោះបីថ្ងៃក្រោយមានការប្រែប្រួលអ្នកដឹកនាំ ឬធ្វើការផ្ទេរនៅសិទ្ធិលើការគ្រប់គ្រងនៃ ដីសម្បទាននេះទៅអោយក្រុមហ៊ុនផ្សេង ឬតតីយជនក៏ដោយ ភាគីក្រុមហ៊ុននឹងបញ្ចូលនូវឯកសារនៃកិច្ច ព្រមព្រៀងនេះទៅក្នុងកិច្ចសន្យាសម្បទានបន្ត ឬកិច្ចសន្យាលក់សិទ្ធិសម្បទាននោះ ឬកិច្ចសន្យាផ្សេងៗរបស់ ក្រុមហ៊ុន និងភាគីក្រុមហ៊ុនមានកាតព្វកិច្ចបំពេញនូវចំនួនថវិកា និងពេលវេលាដែលបានព្រមព្រៀងគ្នាដូចមាន ចែងក្នុងប្រការ១ ខាងលើ ទោះក្នុងលក្ខខណ្ឌមានការប្តូរអ្នកដឹកនាំ ឬប្តូរទៅក្រុមហ៊ុនផ្សេងក៏ដោយ។

4.2- **The Company Party** warrants that regardless of any future change in the management or the transfer of management rights on the concession to other companies or third parties, **the Company Party** will incorporate this agreement document in the transferred Concession Agreement or the contract for the sale of the concession rights, **the Company Party** is obliged to fulfill the agreed budget and time as stated in Article 1 above, even if there is a change of leadership or a transfer to another company.

៤.៣- ភាគីក្រុមហ៊ុនមានកាតព្វកិច្ចអនុវត្តនូវគ្រប់ប្រការទាំងអស់ដូចមានចែងនៅក្នុងកិច្ចព្រមព្រៀងនេះ ឲ្យស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

4.3- **The Company Party** is obliged to carry out all the provisions of this Agreement in accordance with the laws of the Kingdom of Cambodia.



first class
in pursuit of speed and quality

**First-Class Solutions Ltd.**, registered under No. Co. 13113/09P
with the Ministry of Commerce of the Kingdom of Cambodia

#12 Street 222, Phnom Penh, Cambodia
+855 23 214 142 / 12 925 789 / 18 960 748 / 78 567 863
fcinfo@firstclass.com.kh | www.firstclass.com.kh
(IMG2021)

Phnom Penh, September 17, 2021
*This is to certify that this translation correctly corresponds to all the essential particulars of the attached document. It does not establish the authenticity of the original document or the correctness of the contents herein.*

FIRST-CLASS SOLUTIONS LTD

CHAN Sopheap, Translation PM LIM Kruy, CEO

## ប្រការ ៥.- ការមិនគោរព ឬបំពានកិច្ចព្រមព្រៀង

## Article 5.- Default or Violations of Agreement

៥.១- ក្នុងករណីភាគីសហគមន៍ បានបំពាន ឬមិនគោរពតាមប្រការណាមួយនៃកិច្ចព្រមព្រៀងនេះ ភាគីសហគមន៍ សុខចិត្តទទួលខុសត្រូវតាមច្បាប់នៃព្រះរាជណាចក្រកម្ពុជាដែលមានជាធរមាន។

5.1 - In the event that **the Community Party** violates or fails to comply with any provision of this Agreement, **the Community Party** agrees to be liable under the laws of the Kingdom of Cambodia in force.

៥.២- ក្នុងករណីភាគីក្រុមហ៊ុនបានបំពាន ឬមិនគោរពតាមប្រការណាមួយនៃកិច្ចព្រមព្រៀងនេះ ភាគីក្រុមហ៊ុនសុខ ចិត្តទទួលខុសត្រូវតាមច្បាប់នៃព្រះរាជណាចក្រកម្ពុជាដែលមានជា ធរមាន។

5.2- In the event that **the Company Party** has violated or failed to comply with the provisions of this Agreement, **the Company Party** undertakes to be held responsible before the applicable laws of the Kingdom of Cambodia.

៥.៣-ក្នុងករណីដែលបំពាន ឬមិនគោរពដូចមានចែងក្នុងចំណុច៥.១ ឬ៥.២ខាងលើ ហើយ បណ្តាលអោយមានការ ខូចខាតកើតឡើងលើផ្នែករូបីយវត្ថុ(សាច់ប្រាក់ឬ លុយ) ឬលើផ្លូវចិត្ត ឬលើផលប្រយោជន៍ផ្សេងៗរបស់ ភាគីម្ខាងទៀតនោះ ភាគីដែលរំលោភកិច្ចព្រមព្រៀងនេះនឹងទទួលខុសត្រូវចំពោះមុខច្បាប់ និងមានកាតព្វកិច្ច ត្រូវធានាសងចំពោះការខូចខាតទាំងឡាយដែលកើតមានចំពោះភាគីម្ខាងទៀត លើរាល់ការចំណាយនៃការខូច ខាត ថ្លៃសំណងជំងឺចិត្ត ថ្លៃសេវាផ្សេងៗ រួមទាំងថ្លៃមេធាវី ដែលអាចកើតមានឡើងដោយសារ ការរំលោភបំពានកិច្ចព្រមព្រៀងនេះ។

5.3- In the event that any violations or non-compliance as stated in point 5.1 or 5.2 above results in damage both monetarily (cash or money) and emotionally and to other interests of the other party, the violating party shall assume legal responsibility and shall be liable for paying damages incurred by the other party for all costs of damages, fees including attorneys' fees that may incur as a result of the breach of this Agreement.

## ប្រការ ៦.- ការអនុវត្តកិច្ចព្រមព្រៀង ការរំលាយកិច្ចព្រមព្រៀង វិសោធនកម្ម ឬកែប្រែកិច្ចព្រមព្រៀង និងនីតិវិធីនៃការដោះស្រាយវិវាទសម្រាប់ការរំលោភបំពានលើការមិនគោរពកិច្ចព្រមព្រៀង

## Article 6.- Implement agreements, dissolve agreements, amend or change agreements and procedures for resolving disputes for violation or breach of the Agreement



first class
In pursuit of speed and quality

**First-Class Solutions Ltd.**, registered under No. Co. 13113/09P
with the Ministry of Commerce of the Kingdom of Cambodia

#12 Street 222, Phnom Penh, Cambodia
+855 23 214 142 / 12 925 789 / 18 960 748 / 78 567 863
fcinfo@firstclass.com.kh | www.firstclass.com.kh
*(IMG2021)*

Phnom Penh, September 17, 2021
*This is to certify that this translation correctly corresponds to all the essential particulars of the attached document. It does not establish the authenticity of the original document or the correctness of the contents herein.*

FIRST-CLASS SOLUTIONS LTD

**CHAN Sopheap**, Translation PM **LIM Kruy**, CEO

៦.១- **ភាគីទាំងអស់**ត្រូវសហការគ្នាអនុវត្តកិច្ចព្រមព្រៀងអោយបានទៀងទាត់ ពេញលេញ និងត្រឹមត្រូវតាមកិច្ច ព្រមព្រៀង ប្រកបដោយបរិយាកាសស្មោះត្រង់ និងទុកចិត្តគ្នាទៅវិញទៅមក។ ករណីភាគីណាមួយខកខាន មិនបានអនុវត្ត ឬអនុវត្តមិនត្រឹមត្រូវ ឬមិនពេញលេញតាមកិច្ចព្រមព្រៀង នោះភាគីដែលរងគ្រោះអាច តម្រូវអោយភាគី ម្ខាងទៀត អនុវត្តអោយបានត្រឹមត្រូវឡើងវិញ។

6.1- **All parties** shall cooperate to implement the agreement regularly, fully and correctly in accordance with the agreement in an honest atmosphere and mutual trust. In the event that one party fails to implement or has improperly or incompletely implemented the agreement, the affected party may require the violation party to re-implementation.

៦.២- ការអនុគ្រោះរបស់ភាគីណាមួយក្នុងការមិនអនុវត្តសិទ្ធិណាមួយរបស់ខ្លួន ដែលកើតចេញពីកិច្ចព្រមព្រៀងនេះ នឹងមិនត្រូវបានបកស្រាយថាភាគីនោះបោះបង់សិទ្ធិរបស់ខ្លួនឡើយ ។

6.2– The favors of any party to another party in the exercise of any of its rights arising from this Agreement shall not be construed as a waiver of that right.

➢ រាល់ការព្រមព្រៀងពីមុនមករវាង**ភាគីទាំងពីរ**ទោះដោយផ្ទាល់មាត់ក្តី ជាលាយលក្ខណ៍អក្សរក្តី ដែលមាន ខ្លឹមសារផ្ទុយនឹងកិច្ចព្រមព្រៀងនេះ ត្រូវទុកជាមោឃៈ និងមិនអាចអនុវត្តបាន។ រាល់ការកែខ្លឹមសារ ផ្សេងៗនៃកិច្ចព្រមព្រៀងនេះនឹងមានប្រសិទ្ធិភាពតាមផ្លូវច្បាប់ លុះត្រាតែបានធ្វើឡើងជាលាយលក្ខណ៍អក្សរ និងចុះហត្ថលេខា ឬផ្តិតមេដៃព្រមព្រៀង ដោយ**ភាគីទាំងពីរ**។

Any agreements prior to the mediation between **both parties**, whether oral or written, that is contrary to this agreement shall be null and void. Any amendment to the terms of this Agreement shall be legally binding only if it is in writing, signed or thumb printed by **both parties**.

➢ ក្នុងករណីប្រការណាមួយ ឬខ្លឹមសារណាមួយនៃកិច្ចព្រមព្រៀងត្រូវបានច្បាប់ចាត់ទុកជាមោឃៈនោះ ប្រការ ឬ ខ្លឹមសារដ៏ទៃទៀតនៃកិច្ចព្រមព្រៀងនេះនៅតែមានអានុភាពអនុវត្តតាមផ្លូវច្បាប់ដដែល ។

In the event that any provision or content of this agreement is invalidated by law, the other provisions or contents of this agreement shall remain in force.



**First-Class Solutions Ltd.**, registered under No. Co. 13113/09P
with the Ministry of Commerce of the Kingdom of Cambodia

first class
in pursuit of speed and quality

#12 Street 222, Phnom Penh, Cambodia
+855 23 214 142 / 12 925 789 / 18 960 748 / 78 567 863
fcinfo@firstclass.com.kh | www.firstclass.com.kh
(IMG2021)

Phnom Penh, September 17, 2021
*This is to certify that this translation correctly corresponds to all the essential particulars of the attached document. It does not establish the authenticity of the original document or the correctness of the contents herein.*

FIRST-CLASS SOLUTIONS LTD

CHAN Sopheap, Translation PM    LIM Kruy, CEO

៦.៣- បើមានហេតុការណ៍អ្វីកើតឡើងជាយថាហេតុដោយពុំបានចែងក្នុងកិច្ចព្រមព្រៀងនេះ ភាគីណាមួយ ឬភាគី **ទាំងពីរ**ត្រូវកោះប្រជុំដើម្បីពិភាក្សាគ្នា ឬកែប្រែប្រការណាមួយក្នុងកិច្ចព្រមព្រៀងនេះតាមស្មារតីយោគយល់ គ្នា។

6.3- If any eventual event arises that is not stated in this agreement, either or **both parties** shall convene a meeting to discuss or amend any provision of this agreement in a spirit of mutual understanding.

៦.៤- ករណីមានវិវាទបណ្ដាលមកពីការអនុវត្តកិច្ចព្រមព្រៀងនេះ ឬក្នុងករណីភាគីណាមួយមិនអនុវត្តកាតព្វកិច្ចក្នុងកិច្ចព្រមព្រៀងនេះ **ភាគីទាំងពីរ** ត្រូវចរចារ ឬសម្រុះសម្រួល គ្នាឲ្យអស់លទ្ធភាពជាមុនសិនមុននឹងប្ដឹងទៅតុលាការ។ ក្នុងរយៈពេល៦០(ហុកសិប)ថ្ងៃ បើមិនអាចដោះស្រាយវិវាទគ្នាបានដោយជោគជ័យទេ នោះ**ភាគីទាំងពីរ** អាចធ្វើ ការដោះស្រាយតាមរយៈអ្នកសម្រុះសម្រួលឯករាជ្យណាមួយ ឬយន្តការណាមួយតាមផ្លូវ ច្បាប់ជាធរមាន បើមិនអាចដោះស្រាយវិវាទបានដោយជោគជ័យទេ **ភាគីរងគ្រោះ** ឬភាគីម្ខាងទៀតមានសិទ្ធិប្ដឹងរំលាយកិច្ចព្រមព្រៀងនេះបានតាមផ្លូវតុលាការនៃ ព្រះរាជាណាចក្រកម្ពុជាជាអ្នកដោះស្រាយ និងអនុត្តតាមច្បាប់នៃកម្ពុជាជាអ្នកដោះស្រាយ។

6.4- In the event of a dispute arising out of the implementation of this agreement or in the event that either party fails to perform the obligations under this agreement, **both parties** shall first negotiate to the fullest extent before filing a lawsuit to the court. If the dispute cannot be resolved successfully within 60 (sixty) days, both parties can resolve it through any independent mediator or any legal mechanism in force if the dispute cannot be resolved successfully. The affected party or the other party has the right to dissolve this agreement through the courts of the Kingdom of Cambodia.

៦.៥- ការជូនដំណឹងជាផ្លូវការរវាង**ភាគីទាំងពីរ**អាចធ្វើ ឬត្រូវធ្វើជាលាយលក្ខណ៍អក្សរតាមគ្រប់រូបភាព និងអាចបញ្ជូនទៅអាស័យដ្ឋានរបស់ភាគីនិមួយៗ ឬទីតាំងផ្ទះដូចមានបញ្ជាក់ខាងលើ ឬអាចបញ្ជូនតាមរយៈភ្នាក់ងាររត់សំបុត្រ ឬ សារអេឡិចត្រូនិច ឬតាមទូរស័ព្ទក៏បានដោយភាគីទាំងពីរយល់ព្រមគ្នាថាការបញ្ជូនព័ត៏មាននេះត្រូវបានចាត់ទុកថាភាគីម្ខាងទៀតបាន ទទួលព័ត៏មានត្រឹមត្រូវតាមច្បាប់ហើយ។

6.5- Formal notification between the **two parties** may be made in writing in any form and may be sent to the address of each party or to the address as specified above, or may be sent by courier or e-mail or telephone, through which both parties agree that the communication of this information is



first class
in pursuit of speed and quality

**First-Class Solutions Ltd.**, registered under No. Co. 13113/09P with the Ministry of Commerce of the Kingdom of Cambodia

#12 Street 222, Phnom Penh, Cambodia
+855 23 214 142 / 12 925 789 / 18 960 748 / 78 567 863
fcinfo@firstclass.com.kh | www.firstclass.com.kh
*(IMG2021)*

Phnom Penh, September 17, 2021
*This is to certify that this translation correctly corresponds to all the essential particulars of the attached document. It does not establish the authenticity of the original document or the correctness of the contents herein.*

FIRST-CLASS SOLUTIONS LTD

**CHAN Sopheap**, Translation PM **LIM Kruy**, CEO

deemed that the other party has received the information in accordance with the law.

៦.៦- ភាគីអាចរំលាយកិច្ចព្រមព្រៀងសះជានេះបានតាមការព្រមព្រៀងរបស់ភាគីទាំងពីរ។

6.6- The parties may dissolve this settlement agreement as agreed by both parties.

## ប្រការ ៧.- ឆន្ទៈ និងសមត្ថភាពរបស់ភាគី

## Article 7.-Willingness and Capacity of Parties

៧.១- ភាគីទាំងអស់មានឆន្ទៈរួមគ្នាដើម្បីបង្កើតកិច្ចព្រមព្រៀងនេះឡើងដោយគ្មានការបង្ខិតបង្ខំ ឬការគំរាមកំហែងពីភាគីណាមួយនោះឡើយ។

7.1- Both parties are willing to enter into this Agreement without coercion or threat from any party.

៧.២-**ភាគីទាំងពីរ** បានអាន បានស្តាប់យល់ និងមានសមត្ថភាពយល់ដឹងនូវខ្លឹមសារបានគ្រប់ប្រការទាំងអស់ដូចដែលមានចែងក្នុងកិច្ចព្រមព្រៀងនេះ ដោយសន្យាថានឹងអនុវត្តគ្រប់ប្រការទាំងអស់នៃកិច្ចព្រមព្រៀងនេះឲ្យបានត្រឹមត្រូវ និងស្របតាមច្បាប់។

7.2- **Both parties** have read, been read out and have the competence to fully understand all the provisions hereof, undertaking to duly carry out all the provisions of this Agreement in accordance with the law.

៧.៣- **ភាគីសហគមន៍**ទទួលស្គាល់ថាខ្លួនបានទទួលការពន្យល់ បកស្រាយ បានអាន បានយល់ និងបានស្តាប់យល់ នូវខ្លឹមសារនៃកិច្ចព្រមព្រៀងនេះតាំងពីដើម រហូតដល់ថ្ងៃចុះកិច្ចព្រមព្រៀង។

7.3 **The Community Party** acknowledges that it has received an explanation, interpretation, has read, been read out and fully understand of the contents of this Agreement from the beginning until the date of signing the Agreement.

## ប្រការ ៨.- ច្បាប់នៃកិច្ចព្រមព្រៀង និង ភាសាដែលប្រើក្នុងកិច្ចព្រមព្រៀង

## Article 8.- Counterpart, language used in the agreement

៨.១- ភាគីទាំងអស់ឯកភាពគ្នាទទួលយកច្បាប់នៃព្រះរាជាណាចក្រកម្ពុជាជាច្បាប់នៃការអនុវត្ត និងការបកស្រាយ កិច្ចព្រមព្រៀងនេះជាគោល។

8.1- All parties agree that the laws of the Kingdom of Cambodia shall be the principal laws governing the performance and interpretation of this Agreement.

៨.២-កិច្ចព្រមព្រៀងនេះត្រូវធ្វើឡើងជាភាសាខ្មែរ និងមានការបកប្រែជាភាសាអង់គ្លេស នៅក្នុងភាសានីមួយៗ និង គ្រប់ច្បាប់ទាំងនេះត្រូវចាត់ទុកជាលិខិតតួបករណ៍ ឬលិខិតផ្លូវការតែមួយ



first class
in pursuit of speed and quality

**First-Class Solutions Ltd.**, registered under No. Co. 13113/09P with the Ministry of Commerce of the Kingdom of Cambodia

#12 Street 222, Phnom Penh, Cambodia
+855 23 214 142 / 12 925 789 / 18 960 748 / 78 567 863
fcinfo@firstclass.com.kh | www.firstclass.com.kh
*(IMG2021)*

Phnom Penh, September 17, 2021
*This is to certify that this translation correctly corresponds to all the essential particulars of the attached document. It does not establish the authenticity of the original document or the correctness of the contents herein.*

FIRST-CLASS SOLUTIONS LTD

CHAN Sopheap, Translator PM LIM Kruy, CEO

និងដូចៗគ្នា។ ក្នុងករណីមានភាព ខុសគ្នារវាងអត្ថបទជាភាសាខ្មែរ និងអត្ថបទជាភាសាអង់គ្លេស ភាសាខ្មែរត្រូវប្រើជាអត្ថបទគោលក្នុងការបក ស្រាយកិច្ចព្រមព្រៀងនេះ។

8.2- This agreement shall be made in Khmer and accompanied with English translation in each language, all of which taken together shall constitute one and the same instrument or official instrument. In the event of any inconsistency between Khmer and English versions of the Agreement, the Khmer version of the Agreement shall be the prevailing text in the interpretation of this Agreement.

## ប្រការ ៩.- អវសានប្បញ្ញត្តិនៃកិច្ចព្រមព្រៀង

Ariticle 9.- Final provisions of the Agreement

៩.១- កិច្ចព្រមព្រៀងនេះត្រូវបានធ្វើឡើងជាភាសាខ្មែរ និង អង់គ្លេស ចំនួន ០៦ (ប្រាំមួយ) ច្បាប់ដើមក្នុងមួយភាសា ដែលមានតម្លៃគតិយុត្តស្មើគ្នា និងដូចគ្នា ហើយត្រូវរក្សាទុកនៅភាគីសហគមន៍ ចំនួន ០១(មួយ)ច្បាប់ដើម, ភាគីក្រុមហ៊ុន ចំនួន០២ (ពីរ)ច្បាប់ដើម (សម្រាប់ក្រុមហ៊ុនវ៉ារ៉ាណាស៊ី ០១ច្បាប់ និងក្រុមហ៊ុនសេដ្ឋិកុលា ០១ច្បាប់), អ្នកសម្រុះសម្រួល ចំនួន០១(មួយ)ច្បាប់ដើម, តម្កល់នៅសាលាស្រុកពេជ្រាដា ចំនួន ០១(មួយ)ច្បាប់ និង ០១(មួយ)ច្បាប់ដើម សម្រាប់មេធាវីរបស់ភាគីសហគមន៍ភូមិពូទឺត (អង្គការជំនួយ ផ្នែកច្បាប់នៃកម្ពុជា)។

9.1- This Agreement is made in Khmer and English into 06 (six) originals of the same and equal legal force and effect and 01 (one) original of which shall be retained with **the Community Party**, 02(two) original of which shall be retained with **the Company Party**, 01(one) original of which shall be retained with the mediator, filed at Pichreada district Hall and with the Pu Raining community's lawyers (Legal Aid of Cambodia) respectively.

៩.២- គ្រប់ភាគីទាំងអស់ ត្រូវបានចងកាតព្វកិច្ច ចំពោះលក្ខខណ្ឌនៅក្នុងកិច្ចព្រមព្រៀងនេះ និងត្រូវចុះហត្ថលេខា ឬផ្តិតស្នាមមេដៃស្តាំលើកិច្ចព្រមព្រៀង ដើម្បីជាសក្ខីភាព ឬការបញ្ជាក់នៃការចូលរួមរបស់ខ្លួន ។

9.2- All parties are bound by the terms of this Agreement and shall affix their signatures or right thumbprints on the Agreement as testimony or in the acknowledgement of their acceptance.

៩.៣-កិច្ចព្រមព្រៀងនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខា ឬផ្តិតស្នាមមេដៃនេះតទៅ។

9.3- This agreement is effective from the date of signing or affixing thumbprints.



first class
in pursuit of speed and quality

**First-Class Solutions Ltd.**, registered under No. Co. 13113/09P with the Ministry of Commerce of the Kingdom of Cambodia

#12 Street 222, Phnom Penh, Cambodia
+855 23 214 142 / 12 925 789 / 18 960 748 / 78 567 863
fcinfo@firstclass.com.kh | www.firstclass.com.kh
*(IMG2021)*

Phnom Penh, September 17, 2021
*This is to certify that this translation correctly corresponds to all the essential particulars of the attached document. It does not establish the authenticity of the original document or the correctness of the contents herein.*

FIRST-CLASS SOLUTIONS LTD.

**CHAN Sopheap**, Translation PM    **LIM Kruy**, CEO

## ភាគីសហគមន៍

Community Party

| ង៉ាន យិន | ធីន ស៊ីម៉ា | ធឿន ម៉ាប់ | កប់ លេត | កេត ផល្លិត |
|---|---|---|---|---|
| (Ngang Yin) | (Thin Sima) | (Theoun Mab) | (Korb Let) | (Ket Phallit) |

## ភាគីក្រុមហ៊ុន

**Company Party**

| ក្រុមហ៊ុនវ៉ារ៉ាណាស៊ី<br>**Varanasi Company** | ក្រុមហ៊ុនសេដ្ឋីកុលា<br>**Sethikula Company** |
|---|---|
| VARANASI Co., Ltd. | SETHIKULA Co., Ltd. |
| [redacted] | [redacted] |



first class
in pursuit of speed and quality

**First-Class Solutions Ltd.**, registered under No. Co. 13113/09P
with the Ministry of Commerce of the Kingdom of Cambodia

#12 Street 222, Phnom Penh, Cambodia
+855 23 214 142 / 12 925 789 / 18 960 748 / 78 567 863
fcinfo@firstclass.com.kh | www.firstclass.com.kh
*(IMG2021)*

Phnom Penh, September 17, 2021
*This is to certify that this translation correctly corresponds to all the essential particulars of the attached document. It does not establish the authenticity of the original document or the correctness of the contents herein.*

FIRST-CLASS SOLUTIONS LTD

**CHAN Sopheap**, Translation PM **LIM Kruy**, CEO

## សាក្សី

## Witnesses

តំណាងចាស់ទុំភូមិពូទឺត

**Representatives of the elders Pu Teut**

តំណាងអាជ្ញាធរស្រុកពេជ្រាដា

**Pichreada District Authority**

លោក សឹង ត្រាក

**Mr. Soeng Trak**

លោកស្រី ក្លិន ចេល

**Ms. Klin Chel**

លោក ខាំ ផងជា

**Kham Phangchea**

មេធាវីរបស់ភាគីសហគមន៍

អ្នកសម្រុះសម្រួល

មេធាវី ធឿន ពុទ្ធារិទ្ធ

**Thoeung Puthearith**

មេធាវី រុន សារ៉ាយ

**Run Saray**

លោក ប៉ូច សោភ័ណ

**Mr. Poch Sophorn**

ក្រុមសម្រុះសម្រួលឯករាជ្យ

**Independent Mediation Team**



first class
in pursuit of speed and quality

First-Class Solutions Ltd., registered under No. Co. 13113/09P
with the Ministry of Commerce of the Kingdom of Cambodia

#12 Street 222, Phnom Penh, Cambodia
+855 23 214 142 / 12 925 789 / 18 960 748 / 78 567 863
fcinfo@firstclass.com.kh | www.firstclass.com.kh
(IMG2021)

Phnom Penh, September 17, 2021
*This is to certify that this translation correctly corresponds to all the essential particulars of the attached document. It does not establish the authenticity of the original document or the correctness of the contents herein.*

FIRST-CLASS SOLUTIONS LTD

CHAN Sopheap, Translation PM LIM Kruy, CEO

## បានឃើញ និងបញ្ជាក់ថា

**Seen and certified that**

ភាគីទាំងអស់ពិតជាបានព្រមព្រៀងគ្នា និងបានចុះហត្ថលេខា ឬផ្ដិតមេដៃចំពោះមុខពិតប្រាកដមែន។

Both Parties have agreed to the Agreement and affixed their thumbprints in my presence

ធ្វើនៅឃុំប៊ូស្រា, ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២១

Date:

អាជ្ញាធរឃុំប៊ូស្រា

**Busra Commune Authority**

យើត_សារីន



**First-Class Solutions Ltd.**, registered under No. Co. 13113/09P
with the Ministry of Commerce of the Kingdom of Cambodia

#12 Street 222, Phnom Penh, Cambodia
+855 23 214 142 / 12 925 789 / 18 960 748 / 78 567 863
fcinfo@firstclass.com.kh | www.firstclass.com.kh
*(IMG2021)*

Phnom Penh, September 17, 2021
*This is to certify that this translation correctly corresponds to all the essential particulars of the attached document. It does not establish the authenticity of the original document or the correctness of the contents herein.*

**CHAN Sophean**, Translation PM **LIM Kruy**, CEO